**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ....៤៣៤.......ស.ភ.រ

# សេចក្តីជូនដំណឹង

សាលាភូមិន្ទរដ្ឋបាល សូមជម្រាបដល់ សិស្សមន្ត្រីក្រមការជំនាន់ទី៧ កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់-មធ្យមឆ្នាំ២០១៦ សិក្ខាកាមវគ្គខ្លីនៃក្រសួងអប់រំ យុវជន និងកីឡា និងកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់-មធ្យម ឆ្នាំ២០១៧ ព្រមទាំងមន្ត្រីសាលាភូមិន្ទរដ្ឋបាលទាំងអស់ សូមជ្រាបថា ពិធីបិទវគ្គប្រគល់វិញ្ញាបនបត្រ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៧របស់សាលាភូមិន្ទរដ្ឋបាល នឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧** វេលាម៉ោង០៧:០០ នាទីព្រឹក នៅវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត**។

អាស្រ័យដូចនេះ សូមអញ្ជើញចូលរួមប្រជុំ និងទទួលការណែនាំអំពីដំណើរការនានាពាក់ព័ន្ធនឹងពិធីបិទបើកវគ្គខាងមុខនេះ **នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧** នៅសហសាល នៃសាលាភូមិន្ទរដ្ឋបាល តាមការបែងចែក និងកំណត់ដូចតខាងក្រោម៖

- **វេលាម៉ោង១:៣០នាទីរសៀល៖** សិស្សមន្ត្រីក្រមការជំនាន់ទី៧ និងសិក្ខាកាមវគ្គគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា។
- **វេលាម៉ោង៣:០០នាទីរសៀល៖** កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់-មន្ត្រីមធ្យម ឆ្នាំ២០១៦។
- **វេលាម៉ោង៤:២០នាទីរសៀល៖** កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់-មន្ត្រីមធ្យម ឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសិស្សមន្ត្រីក្រមការជំនាន់ទី៧ កម្មសិក្សាការី និងសិក្ខាកាម នៃសាលាភូមិន្ទរដ្ឋបាលទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមជាកំហិត។

*<u>សំណៀកបំពាក់</u>* ៖ ឯកសណ្ឋានសាលា

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧

**សាលាភូមិន្ទរដ្ឋបាល**

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញឹកថូឡុង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658

អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh